ក្រសួងអប់រំរដ្ឋ NSW

Learning to work with letters and numbers

Family resources

# ការរៀនធ្វើការជាមួយអក្សរ និងលេខ

## ធនធានសម្រាប់គ្រួសារ



ក្របខ័ណ្ឌការរៀនសូត្រសម្រាប់កុមារតូច (Early Years Learning Framework) គឺជាក្របខ័ណ្ឌជាតិលើការរៀនសូត្រ  ដែលត្រូវបានប្រើនៅក្នុងមត្តេយ្យសាលា និងសេវាកម្មកុមារតូចទាំងអស់។ វាណែនាំការបង្រៀន និងការរៀនសូត្រដោយមានលទ្ធផលនៃការរៀនសូត្រចំនួនប្រាំ ដែលជួយឱ្យកុមារក្លាយជាអ្នករៀនពូកែ និងមានសមត្ថភាព។

លទ្ធផលនៃការរៀនសូត្រទី 5 គឺអំពីកុមារក្លាយជាអ្នកទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។ នេះមានន័យថា ពួកគេអាចរៀនអំពីភាសា ស្តាប់ និងឆ្លើយតបទៅនឹងសម្លេង និងលំនាំក្នុងការនិយាយស្តី រឿង និងបទចម្រៀង។ កុមារអាចប្រើបច្ចេកវិទ្យានៅក្នុងជីវិតប្រចាំថ្ងៃ ដើម្បីរុករកព័ត៌មានថ្មីៗ និងតំណាងគំនិតរបស់ពួកគេ។ ពួកគេរៀនអំពីគំនិតគណិតវិទ្យាដូចជាចំនួន ការរាប់ រង្វាស់រង្វាល់ និងរាង។

សួករំកមាប់ព័ត៌មានបដែដ ្មអំពី Early Years Learning Framework សូមចូលទៅមើល៖

https://www.education.gov.au/collections/translations-belonging-being-and-becoming-early-years-learning-framework-australia

### សេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទាក់ទងមកមត្តេយ្យសាលា ឬសេវាកម្មសម្រាប់កុមារតូចរបស់អ្នក។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាផ្ទាល់មាត់ ដើម្បីជួយក្នុងការសាកសួររបស់អ្នក សូមទូរស័ព្ទទៅសេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ លេខ 131 450 ហើយស្នើសុំអ្នកបកប្រែជាភាសារបស់អ្នក។ ប្រតិបត្តិករនឹងហៅលេខទូរស័ព្ទដែលអ្នកផ្តល់ឱ្យ ហើយរៀបចំអ្នកបកប្រែភាសាតាមទូរស័ព្ទជូនអ្នក ដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។

# ការរៀនសូត្រនៅសាលារៀន

## ការរៀនសូត្រសម្រាប់កុមារតូច

### ជាអ្នកទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព មានន័យថា៖

- កុមារអាចស្តាប់ យល់ និងបង្កើតរឿង និងចម្រៀង
- កុមារចែករំលែករឿងពីវប្បធម៌ផ្ទាល់ខ្លួន និងភាសារបស់ពួកគេ
- កុមារអាចប្រាស្រ័យទាក់ទង និងចែករំលែកអ្វីដែលពួកគេបានរៀនតាមរយៈតន្ត្រី ការសម្តែងសិល្បៈ និងរបាំ
- កុមារដឹងថាពួកគេអាចប្រើលេខ ការរាប់ និងការវាស់វែងនៅក្នុងជីវិតប្រចាំថ្ងៃ

- សិស្សអាចអភិវឌ្ឍ និងបញ្ចេញគំនិតផ្ទាល់ខ្លួនរបស់ពួកគេ (មុខវិជ្ជា៖ ភាសាអង់គ្លេស និងគណិតវិទ្យា)
- សិស្សអាចស្តាប់ និយាយ អាន និងសរសេរដើម្បីប្រាស្រ័យទាក់ទង (មុខវិជ្ជា៖ ភាសាអង់គ្លេស និងគណិតវិទ្យា)
- សិស្សអាចប្រើជំនាញគណិតសាស្ត្រក្នុងជីវិតប្រចាំថ្ងៃ (មុខវិជ្ជា៖ គណិតវិទ្យា)
- សិស្សអាចប្រើបច្ចេកវិទ្យានៅសាលារៀន និងក្នុងជីវិតប្រចាំថ្ងៃដើម្បីប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ (មុខវិជ្ជា៖ បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង)